# បណ្ណលេខ១: តើអ្វីទៅជាអូទីស្សឹម?







**រដ្ឋា** ជាកុមារមានអូទីស្សឹម ការទំនាក់ទំនងរបស់គាត់ដូចជា ការយល់ដឹង ការគិត និង អារម្មណ៍ គឺមានលក្ខណៈផ្សេងពីកុមារដទៃ។ អូទីស្សឹម គឺជាវិបល្លាសការអភិវឌ្ឍដែលមានការប៉ះពាល់ដល់ការទំនាក់ទំនង និងអាកប្បកិរិយា។ កុមារមានអូទីស្សឹម ដូច**រដ្ឋា** មានផលលំបាកក្នុងការប្រាស្រ័យទាក់ទងសង្គម ការទំនាក់ទំនង និងអាកប្បកិរិយាដដែលៗ។

# ព័ត៌មានបន្ថែម៖

- អូទីស្សឹមគឺជាបណ្តុំវិបល្លាស ដែលមានន័យថា មានរោគសញ្ញាផ្សេងៗជាច្រើន និងភាពធ្ងន់ធ្ងរ។
- អូទីស្សឹមគឺជាវិបល្លាសការអភិវឌ្ឍ ដែលមានផលប៉ះពាល់ដល់ការទំនាក់ទំនង និងអាកប្បកិរិយា។ កុមារដែលមានអូទីស្សឹមមានផលលំបាកក្នុងការប្រាស្រ័យទាក់ទងសង្គម ទំនាក់ទំនង និងអាកប្បកិរិយាដដែលៗ។
- អូទីស្សឹមជាទូទៅបណ្តាលមកពីការពាក់ព័ន្ធនឹងតំណពូជ និងកត្តាបរិស្ថានផ្សេងៗ។
- អូទីស្សឹមគឺមានលក្ខណៈរ៉ាំរ៉ៃ ដូចជា ជំងឺទឹកនោមផ្អែម និងលើសសម្ពាធឈាមដែរ។ វាពុំអាចព្យាបាលបានទេ ប៉ុន្តែមានវិធីដែលអាចជួយ និងគាំទ្រកុមារឲ្យគេអាចចូលសាលារៀនបាន និងអភិវឌ្ឍដូចកុមារដទៃទៀតដែរ។


សហការផលិតដោយ

ក្រោមជំនួយឧបត្ថមពី រដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី ACCESS

# បណ្ណលេខ២: តើសញ្ញា និងរោគសញ្ញាអូទីស្សឹមមានអ្វីខ្លះ?









**សញ្ញា និងរោគសញ្ញាអូទីស្សឹមមាន៣ចំណុចចំបងគឺ៖**

- ពិបាកប្រាស្រ័យទាក់ទង និងចូលរួមជាមួយអ្នកដទៃ។
- បញ្ហាទំនាក់ទំនង (ពិបាកក្នុងការបង្ហាញនូវតម្រូវការ និងចង់បានអ្វីមួយ)
- អាកប្បកិរិយាដដែលៗ (លេងជាមួយនឹងប្រដាប់ប្រដាដដែលៗ)





រោគសញ្ញាទាំងនេះអាចខុសគ្នា និងធ្ងន់ធ្ងរ ទៅតាមមនុស្សម្នាក់ៗ។

ដូច្នេះ ត្រូវយល់ថា "**អូទីស្សឹមលក្ខណៈ**" ផ្សេងៗគ្នា។

# ព័ត៌មានបន្ថែម៖

កុមារ ដែលមានអូទីស្សឹមដូចជា**រដ្ឋា** អាចមានផលលំបាកមួយចំនួននៅក្នុងវ័យកុមារភាពរបស់គាត់។ **រដ្ឋា** អាចមិនមានទំនាក់ទំនងតាមរយៈក្រសែភ្នែក (មិនសម្លឹងចំមុខ) នៅពេលម្តាយរបស់គាត់បញ្ចុកអាហារគាត់។ គាត់ចូលចិត្តនៅម្នាក់ឯង មិនលេងជាមួយបងប្អូនរបស់គាត់ និងមិនឆ្លើយនៅពេលដែលម្តាយ ឬសមាជិកគ្រួសារហៅគាត់។

កុមារមានអូទីស្សឹម អាចមិនចង្អុល ឬបង្ហាញរបស់អ្វីមួយ ឧទាហរណ៍ ដូចជា មានផ្លែដើរកាត់ គាត់មិនបាននិយាយថា " **ផ្លែ** " ទេ។ គាត់មានភាពយឺតយ៉ាវក្នុងការនិយាយ មានន័យថា គាត់អាចនិយាយបានប្រហែល ២០ពាក្យ ខណៈដែលកុមារដែលមានអាយុ ៥ឆ្នាំ អាចនិយាយបាន២០០ពាក្យ (មានការអភិវឌ្ឍផ្នែកភាសាយឺតយ៉ាវ)។

កុមារដែលមានអូទីស្សឹម ដូចជា **រដ្ឋា** អាចធ្វើសកម្មភាពអ្វីមួយដដែលៗ ដូចជា តម្រៀបប្រដាប់ប្រដាលេង ទះដៃរបស់គាត់ជាការភ្លេចខ្លួនឯង។ គាត់អាចមានផលលំបាកជាមួយនឹងការផ្លាស់ប្តូរ ទម្លាប់ ដូចជា ការទៅសាលារៀនដោយផ្លូវផ្សេង ឬការប្រើប្រាស់ជាមួយនឹងស្លាបព្រា ឬចានផ្សេង។

*ប្រសិនបើលោកអ្នកមានការព្រួយបារម្ភថា កូនរបស់អ្នកអាចមានអូទីស្សឹម វាមានសារៈសំខាន់ចំពោះអ្នកទៅធ្វើការពិគ្រោះយោបល់ជាមួយអ្នកផ្តល់សេវាសុខភាព ដែលនៅជិតផ្ទះរបស់លោកអ្នក ដូចជា អ្នកទ្រទ្រង់សុខភាពតាមភូមិ ឬបុគ្គលិកមណ្ឌលសុខភាព ដែលពួកគាត់អាចផ្តល់វិធីសាស្រ្ត ដើម្បីជួយកូនរបស់អ្នក ឬជួយបញ្ជូនទៅទទួលសេវាជួយបន្ថែមទៀតនៅកន្លែងផ្សេង។*

សហការផលិតដោយ

ក្រោមជំនួយឧបត្ថមពី រដ្ឋាភិបាលអូស្រ្តាលី តាមរយៈកម្មវិធី ACCESS

# បណ្ណលេខ៣: ការកត់សម្គាល់បញ្ហាឲ្យបានទាន់ពេលវេលា



ការកត់សម្គាល់បញ្ហាអូទីស្សឹមឲ្យបានទាន់ពេល គឺមានសារៈសំខាន់ដើម្បីជួយកុមារ ទទួលបានការអភិវឌ្ឍតាមដំណាក់កាលអាយុលូតលាស់បានសមស្រប នៅក្នុងពេលវេលាដ៏សំខាន់នៃការអភិវឌ្ឍខួរក្បាល។ យុទ្ធសាស្ត្រអន្តរាគមន៍ឲ្យបានទាន់ពេល ដូចជាសកម្មភាពតាមរយៈការលេងនៅផ្ទះ អាចជួយឲ្យ **រដ្ឋា** រៀន អភិវឌ្ឍជំនាញ និងជួយឲ្យគាត់ចាប់ផ្តើមចូលរៀនបាន។

1.Flashcard_Level1_V6_Khmer.indd 6 9/6/23 1:05 PM

# ព័ត៌មានបន្ថែម៖

**នេះជាឧទាហរណ៍ជាក់លាក់មួយចំនួននៃការកត់សម្គាល់បញ្ហាឲ្យបានទាន់ពេល និងអន្តរាគមន៍ដែលអាចជួយ រដ្ឋា បាន៖**

- ម្តាយរបស់**រដ្ឋា**មានការព្រួយបារម្ភខ្លាច**រដ្ឋា** មិនអាចនិយាយបានដូចជាបងស្រីរបស់គាត់ ដូចនេះគាត់បានទំនាក់ទំនងជាមួយបុគ្គលិកទ្រទ្រង់សុខភាពតាមភូមិ ដែលមានការបារម្ភណ៍ថា **រដ្ឋា** អាចមានអូទីស្សឹម។
- **ចាន់ធូ** ដែលជាបុគ្គលិកទ្រទ្រង់សុខភាពតាមភូមិ បានផ្តល់យោបល់ដល់ម្តាយ**រដ្ឋា** ឲ្យលេង និងទំនាក់ទំនងជាមួយកូនឲ្យបានញឹកញាប់តាមដែលអាចធ្វើបាន ទោះជាកូនគាត់មិនប្រាស្រ័យទាក់ទងក៏ដោយ។ ធ្វើដូចនេះអាចជួយកុមារអូទីស្សឹមដូចជា **រដ្ឋា** អាចរៀន និងអភិវឌ្ឍភាសា និងជំនាញទំនាក់ទំនងរបស់គេនៅអាយុតិច។
- **ចាន់ធូ**ក៏បានផ្តល់ព័ត៌មានដល់ **ពិសិដ្ឋ** ដែលជាគ្រូមត្តេយ្យ អំពីលក្ខណៈរបស់**រដ្ឋា**។ **ពិសិដ្ឋ**បានយល់ និងគាំទ្រ ដែលនេះអាចជួយឲ្យ**រដ្ឋា** បង្កើតទំនាក់ទំនងជាមួយកុមារដទៃទៀតនៅសាលារៀន។

*ប្រសិនបើលោកអ្នកមានការព្រួយបារម្ភថា កូនរបស់អ្នកអាចមានអូទីស្សឹម វាមានសារៈសំខាន់ចំពោះអ្នក ទៅជួបជាមួយបុគ្គលិក ថែទាំសុខភាព គ្រូបង្រៀន ឬអ្នកជិតខាង ដែលពួកគាត់អាចបញ្ជូនទៅរកទីកន្លែង ឬមជ្ឈមណ្ឌល ដែលអាចផ្តល់ព័ត៌មានដល់អ្នកថាតើកូនរបស់អ្នកមានរោគវិនិច្ឆ័យអូទីស្សឹមដែរ ឬទេ។ ការកំណត់រោគវិនិច្ឆ័យ និងអន្តរាគមន៍បានទាន់ពេលវេលាអាចធ្វើឲ្យមានភាពខុសប្លែកគ្នាធំមួយនៅក្នុងជីវិតរបស់កុមារដែលមានអូទីស្សឹម ដោយជួយឲ្យពួកគេអាចចូលរៀនបាន។*

សហការផលិតដោយ

ក្រោមជំនួយឧបត្ថមពី រដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី ACCESS

Australian Aid

ACCESS Sustainable quality services for all

# បណ្ណលេខ៤: អូទីស្សឹម មានបញ្ហាអភិវឌ្ឍខួរក្បាលមិនមែនជាជំងឺនោះទេ













អូទីស្សឹមមានលក្ខណៈរ៉ាំរ៉ៃ ដូចជាជំងឺទឹកនោមផ្អែម ជំងឺលើសសម្ពាធឈាម ដែលត្រូវការការថែទាំ និងការគាំទ្រអស់មួយជីវិត ។ អូទីស្សឹមគឺជាបញ្ហាទាក់ទងនឹងការអភិវឌ្ឍ ដែលបង្ហាញថាការអភិវឌ្ឍខួរក្បាលរបស់កុមារ គឺមិនដូចកុមារដទៃទៀត។

ទោះបីជាវាមានលក្ខណៈរ៉ាំរ៉ៃ តាមរយៈការគាំទ្រ និងអន្តរាគមន៍តាមរយៈការលេង កុមារដូច**រដ្ឋា** អាចរៀនទំនាក់ទំនង និងប្រាស្រ័យទាក់ទងជាមួយអ្នកដទៃបាន។ ការចុះឈ្មោះឲ្យគាត់ចូលរៀននៅក្នុងសាលាមត្តេយ្យ នឹងជួយសម្របសម្រួលឲ្យមានភាពប្រសើរឡើងបានឆាប់រហ័ស និងជួយ**រដ្ឋា**រៀនបានដូចកុមារដទៃទៀតដែរ។

# ព័ត៌មានបន្ថែម៖

**នេះជាឧទាហរណ៍មួយចំនួន ដែលបង្ហាញថា រដ្ឋា មានលក្ខណៈខុសប្លែកពីកុមារដទៃទៀត៖**

- **រដ្ឋា**មានផលលំបាកក្នុងការប្រាស្រ័យទាក់ទងសង្គម មានន័យថា គាត់មិនមើលមុខអ្នកដទៃ (មិនមានសម្លឹងក្រសៃភ្នែក) និងមិនមានភាពងាយស្រួលក្នុងការសន្ទនា។
- **រដ្ឋា**មានផលលំបាកក្នុងការទំនាក់ទំនង ដូច្នេះហើយមិនអាចបង្ហាញពីតម្រូវការរបស់គាត់ជាពាក្យសំដី និងជាជាងទាញដៃម្តាយរបស់គាត់ដើម្បីបង្ហាញនូវអ្វីដែលគាត់ចង់បាន។
- **ចាន់ណា** ដែលជាម្តាយរបស់**រដ្ឋា** គឺមានការតានតឹងចិត្ត ពីព្រោះកូនគាត់មានអាកប្បកិរិយាដដែលៗ(ធ្វើសកម្មភាពដដែលៗម្តងហើយម្តងទៀត) ដូចជា គូរគំនូរវត្ថុតម្រួតលើគ្នា ឬតម្រៀបឡានជាជួរ និងមានការខឹងសម្បានៅពេលដែលទម្លាប់របស់គាត់បានផ្លាស់ប្តូរ (បញ្ហាអាកប្បកិរិយា)។

*អ្នកថែទាំកុមារ ឬគ្រូបង្រៀនដែលមានការយល់ដឹងពីបញ្ហា អាចដើរតួនាទីគាំទ្រ និងលើកទឹកចិត្តកុមារអូទីស្សឹមឲ្យគេរៀន និងអភិវឌ្ឍជំនាញសមស្រប ដែលនឹងជួយឲ្យកុមារទទួលបានជោគជ័យនៅសាលារៀន។*

សហការផលិតដោយ

ក្រោមជំនួយឧបត្ថមពី រដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី ACCESS

# បណ្ណលេខ៩: ប្រភេទនៃបញ្ហាបន្ថែម (បញ្ហារួមផ្សំផ្សេងៗ)



មានជាងពីរភាគបី (២/៣) នៃកុមារអូទីស្សឹមអាចមានបញ្ហាបន្ថែមផ្សេងៗ ដូចជា ពិការភាពបញ្ញា វិបល្លាសរពឹស និងកង្វះការផ្ចង់អារម្មណ៍ ជំងឺប្រកាច់ អាកប្បកិរិយា និងបញ្ហាគេង។ បញ្ហាទាំងអស់នេះ អាចធ្វើឲ្យមានផលលំបាកជាច្រើនចំពោះកុមារអូទីស្សឹម និងក្រុមគ្រួសាររបស់គេ។ នៅពេលដែលកុមារមានបញ្ហារួមផ្សំផ្សេងៗ ក្រុមគ្រួសារត្រូវការស្វែងរកជំនួយបន្ថែមពីគ្រូពេទ្យចិត្តសាស្រ្ត អ្នកព្យាបាលមុខងារប្រចាំថ្ងៃ/ភាសា និងវេជ្ជបណ្ឌិត។ កុមារអាចត្រូវការប្រើប្រាស់ថ្នាំពេទ្យ ដើម្បីគ្រប់គ្រងបញ្ហារួមផ្សំទាំងអស់នេះ។

1.Flashcard_Level1_V6_Khmer.indd 10 9/6/23 1:05 PM

# ព័ត៌មានបន្ថែម៖

**កុមារអូទីស្សឹមភាគច្រើនអាចមានបញ្ហារួមផ្សំផ្សេងៗ ដូចជា៖**

- មិនអាចអង្គុយនៅនឹងមួយកន្លែងបាន ឬផ្តោតការយកចិត្តទុកដាក់លើសកម្មភាពមួយ ដូចជាការលេងជាមួយតុក្កតា។ បញ្ហានេះឲ្យឈ្មោះថា វិបល្លាសរពឹស និងកង្វះការផ្ចង់អារម្មណ៍ (ADHD) នៅពេលដែលកុមារមិនអាចអង្គុយ និងចូលរួមស្តាប់អ្វីដែលគ្រូកំពុងនិយាយ។
- **រដ្ឋា**មានការថប់បារម្ភ និងយំរាល់ថ្ងៃ នៅពេលដែលគាត់ទៅសាលា ហើយម្តាយរបស់គាត់ត្រូវតែរួមដំណើរជាមួយគាត់ បើមិនដូច្នេះទេ គាត់នឹងមិនទៅសាលារៀនឡើយ (ថប់បារម្ភពីការបែកចេញពីម្តាយ)។
- កុមារជាច្រើនមានផលលំបាកក្នុងការគេងឲ្យបានទៀងទាត់ជាប្រចាំ។ **រដ្ឋា** បានរៀនពីការអនុវត្តនូវទម្លាប់គេងឲ្យបានត្រឹមត្រូវ ដូចជា ងូតទឹកក្តៅអ៊ុនៗ អានសៀវភៅរឿង ជៀសវាងការមើលទូរទស្សន៍ពីរម៉ោងមុនពេលចូលគេង ដែលបានជួយឲ្យ**រដ្ឋា**គេងបានប្រសើរជាងមុន។
- កុមារអូទីស្សឹមមួយចំនួនឆាប់រំភើប ភ្ញាក់ផ្អើលនឹងសំឡេង និងបិទត្រចៀករបស់គេ ហើយមួយចំនួនទៀតមិនចូលចិត្តអាហារណាមួយ ដែលមានពណ៌ ឬសភាពអាហារ ដែលបង្ហាញថាកុមារអាចមានវិបល្លាសដំណើរការញាណ ឬបញ្ហាញាណ ។

សហការផលិតដោយ

ក្រោមជំនួយឧបត្ថមពី រដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី ACCESS

1.Flashcard_Level1_V6_Khmer.indd 11 9/6/23 1:05 PM

# បណ្ណលេខ៦(ក): មិនអាចព្យាបាលឲ្យជានោះទេ ប៉ុន្តែអាចជួយបាន







អូទីស្សឹមគឺជាបញ្ហាអស់មួយជីវិត ប៉ុន្តែបើមានការគាំទ្រគ្រប់គ្រាន់ និងជួយអន្តរាគមន៍បានទាន់ពេលវេលា កុមារអូទីស្សឹមអាចរៀនបានដូចកុមារដទៃ អាចមានមិត្តភក្តិ និងរីករាយនៅក្នុងការសិក្សា។ វាមានសារៈសំខាន់ដែលឪពុកម្ដាយរបស់**រដ្ឋា**យល់ច្បាស់ថា អូទីស្សឹមគឺមិនអាចព្យាបាលឲ្យជានោះទេ ប៉ុន្តែមានចំណុចជាច្រើនដែលគាត់អាចធ្វើនៅផ្ទះ ដើម្បីឲ្យ**រដ្ឋា**អាចរៀន និងអភិវឌ្ឍជំនាញសង្គម និងទំនាក់ទំនងតាមរយៈយុទ្ធសាស្ត្រសាមញ្ញ ដូចខាងក្រោម:

- កត់សម្គាល់បញ្ហាឲ្យបានទាន់ពេលវេលា និងមានសកម្មភាពលេងនៅផ្ទះ
- យុទ្ធសាស្ត្របង្កើនការប្រាស្រ័យទាក់ទង ដោយការឆ្លើយតបភ្លាមៗ បង្ហាត់បង្ហាញពាក្យថ្មីៗពីស្ថានភាពប្រចាំថ្ងៃ

# ព័ត៌មានបន្ថែម៖

**នេះជាឧទាហរណ៍ជាក់លាក់មួយចំនួន ដែលកុមារដូចជា រដ្ឋា អាចត្រូវបានជួយ៖**

- ឪពុកម្តាយរបស់**រដ្ឋា** មានការព្រួយបារម្ភពេល**រដ្ឋា**មានអាយុ១៨ខែ ដែល**រដ្ឋា**មិនអាចទំនាក់ទំនងបានដូចកុមារដទៃ ហើយពួកគាត់បានស្វែងរកការអប់រំ និងគាំទ្រផ្នែកចិត្តសាស្ត្រពីអ្នកព្យាបាល។ វិធីនេះបានជួយ**រដ្ឋា**អភិវឌ្ឍលើផ្នែកទំនាក់ទំនង និងជំនាញក្នុងការជួយខ្លួនឯង ដែលអាចជួយឲ្យគាត់ចុះឈ្មោះចូលរៀនបាន។ ឪពុកម្តាយ**រដ្ឋា** បានសរសើរ**រដ្ឋា** នៅពេលដែលគាត់មានអាកប្បកិរិយាល្អពេលភ្ញៀវមកលេងផ្ទះ ហើយគាត់ធ្វើមិនអើពើចំពោះអាកប្បកិរិយាខឹងមួម៉ៅម្តងម្កាល (ឧៈអាកប្បកិរិយាយំទន្ទ្រាំជើង)នោះទេ។
- ឪពុកម្តាយរបស់**រដ្ឋា** តែងតែអង្គុយចំពីមុខ**រដ្ឋា** ធ្វើតាមសកម្មភាពរបស់កូន ប្រាប់ និងថាឈ្មោះវត្ថុដែលកូនគាត់ជ្រើសរើស ធ្វើដូចនេះដើម្បីបង្កើនជំនាញទំនាក់ទំនងកូនរបស់គាត់។
- ការព្យាបាលមុខងារប្រចាំថ្ងៃ អាចជួយកុមារដែលមានអូទីស្សឹមមានភាពប្រសើរឡើងនូវជំនាញចលនាម្រាមដៃ និងការសម្របសម្រួលចលនា ដូចជា ការសរសេរ ញ៉ាំអាហារ បិទឡេវអាវ ។ល។

សហការផលិតដោយ

ក្រោមជំនួយឧបត្ថមពី រដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី ACCESS

Australian Aid

ACCESS Sustainable quality services for all

1.Flashcard_Level1_V6_Khmer.indd 13 9/6/23 1:05 PM

# បណ្ណលេខ៦(ខ):មិនអាចព្យាបាលឲ្យជានោះទេ ប៉ុន្តែអាចជួយបាន







- ផ្តល់ជារង្វាន់ភ្លាមៗ ដើម្បីឲ្យកុមារប្រព្រឹត្តសកម្មភាពវិជ្ជមាន និងមិនអើពើចំពោះសកម្មភាពណាដែលមិនចង់បាន
- នៅពេលកុមារមានបញ្ហាញាណ ដូចជា រសជាតិ ហិតក្លិន និងសម្លេងជាដើម ។ សូមធ្វើសកម្មភាពមួយចំនួនបន្តិចៗម្តងៗ ដើម្បីឲ្យកុមារទទួលដឹងញាណអំពីបញ្ហាទាំងអស់នេះវិញ។
- នៅពេលមានភ្ញៀវមកលេងផ្ទះ បង្រៀនកូនពីជំនាញសង្គម ដូចជាការជម្រាបសួរភ្ញៀវ។
- ចូលរួមជាសមាជិកក្រុមគាំទ្រ នៃគ្រួសារកុមារអូទីស្ស៊ឹម ដើម្បីចែករំលែក និងរៀនបទពិសោធន៍ពីគ្នាទៅវិញទៅមកជាមួយនឹងការគាំទ្រ និងជួយដ៏ត្រឹមត្រូវ កុមារអូទីស្ស៊ឹមអាចទៅសាលារៀនបានដូចកុមារដទៃទៀតដែរ។

1.Flashcard_Level1_V6_Khmer.indd 14 9/6/23 1:05 PM

# ព័ត៌មានបន្ថែម៖

- ឪពុកម្តាយរបស់**រដ្ឋា** ធ្វើជាគំរូនូវអាកប្បកិរិយាវិជ្ជមាន ដូចជា ជម្រាបសួរគ្រូ គោរពចាស់ទុំ ។ល។ (**ការបង្ហាត់បង្រៀនជំនាញសង្គម**)។ នេះជួយឲ្យ**រដ្ឋា**រៀនពីរបៀបប្រាស្រ័យទាក់ទងជាមួយអ្នកដទៃ។
- ក្រុមជួយគាំទ្រ**រដ្ឋា** មិនមែនគ្រាន់តែមានកូនដែលមានអូទីស្សឹមប៉ុណ្ណោះទេ ប៉ុន្តែពួកគាត់ខ្លះមានជំងឺប្រកាច់ ពិការភាពបញ្ញា និងដោនស៊ីនដ្រូម។ល។

*ឪពុកម្តាយដែលមានកូនជាកុមារអូទីស្សឹម អាចស្វែងរកព័ត៌មាន និងការគាំទ្របានគ្រប់គ្រាន់។*

សហការផលិតដោយ

ក្រោមជំនួយឧបត្ថមពី រដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី ACCESS

# បណ្ណលេខ៧: ការជួយអន្តរាគមន៍តាមរយៈការលេង







**ការជួយអន្តរាគមន៍តាមរយៈការលេង** គឺជាបច្ចេកទេសកុមារដ៏ល្អដែលប្រើសម្រាប់ផ្សារភ្ជាប់ការប្រាស្រ័យទាក់ទងរវាងឪពុកម្តាយ និងកូននៅផ្ទះ ដើម្បីឲ្យកុមារអូទីស្សឹមអភិវឌ្ឍជំនាញបានសមរម្យទៅនឹងដំណាក់កាលលូតលាស់តាមអាយុរបស់គេ។

**ការជួយអន្តរាគមន៍តាមរយៈការលេង** អាចត្រូវបានប្រើដើម្បីជួយកុមារអូទីស្សឹមបង្កើនជំនាញសង្គម ទំនាក់ទំនង និងសមត្ថភាពយល់ដឹង។ **ការជួយអន្តរាគមន៍តាមរយៈការលេង** គឺជាវិធីធ្វើឲ្យកុមារអូទីស្សឹម ឪពុកម្តាយ និងបងប្អូនរបស់គេមានការលេងសប្បាយរីករាយ ដោយមានការប្រាស្រ័យទាក់ទង និងចូលរួមរៀនទាំងអស់គ្នា។

1.Flashcard_Level1_V6_Khmer.indd 16 9/6/23 1:05 PM

# ព័ត៌មានបន្ថែម៖

**សកម្មភាពជាក់លាក់ទាំងអស់នេះ ដែលម្តាយរដ្ឋាបានអនុវត្ត ដោយប្រើប្រាស់វិធីលេងជាមួយរដ្ឋានៅផ្ទះ  បានជួយឲ្យ រដ្ឋាអភិវឌ្ឍជំនាញចាំបាច់ ដូចជា៖**

- **ចាន់ណា**បានដឹងថា **រដ្ឋា**ចូលចិត្តកូនឆ្កែតុក្កតា ដូច្នេះគាត់បានណែនាំពាក្យថ្មីៗមួយចំនួនដូចជា ជើងវែង សក់ពណ៌ត្នោត ឆ្កែគួរឲ្យស្រឡាញ់ ដែលជួយសម្រួលគាត់ឲ្យរៀនពាក្យថ្មី និងប្រាស្រ័យទាក់ទងជាមួយអ្នកដទៃ ដោយពុំមានការថប់បារម្ភ។
- ពាក្យថ្មីៗដែលណែនាំដោយ**ចាន់ណា** តាមរយៈការលេងល្បែងដាក់របស់ក្នុងថង់ ដូចជា មានសត្វ ផ្លែឈើ បន្លែ  និងឡានជាដើម ដែលជាសកម្មភាពសប្បាយៗ ជួយឲ្យ**រដ្ឋា** បង្កើនជំនាញទំនាក់ទំនង។
- បងស្រី**រដ្ឋា**ចូលចិត្តលេងល្បែងផ្គុំរូប បន្ទាប់ពីនាងមកពីសាលារៀនវិញ។ **រដ្ឋា**ចូលចិត្តលេងល្បែងផ្គុំរូបខ្លាំងដែរ ហើយជួយឲ្យ**រដ្ឋា**បង្កើនជំនាញយល់ដឹង។
- **ការជួយអន្តរាគមន៍តាមរយៈការលេ**ង គឺជាការលេងសប្បាយៗ និងជាមធ្យោបាយឲ្យមានការចូលរួមមិនត្រឹមតែជាមួយកុមារអូទីស្ស៊ីមដើម្បីរៀន និងអភិវឌ្ឍជំនាញប៉ុណ្ណោះទេ ប៉ុន្តែនាំឲ្យមានការជុំគ្នាជាមួយនឹងក្រុមគ្រួសារផងដែរ។

*បើលោកអ្នកមានចំណាប់អារម្មណ៍ចង់ដឹងបន្ថែមអំពីការជួយអន្តរាគមន៍តាមរយៈការលេង មានឯកសារជាច្រើននៅលើវ៉ិបសាយក៏ដូចជានៅតាមស្ថាប័នមួយចំនួនដែលផ្តល់សេវានៅក្នុងប្រទេសកម្ពុជា។ អ្នកអាចពិគ្រោះជាមួយអ្នកព្យាបាលដែលបានទទួលការបណ្តុះបណ្តាលពីការជួយអន្តរាគមន៍តាមរយៈការលេង ដើម្បីទទួលបានការណែនាំពីជម្រើសល្បែងនានាដែលសមស្របនឹងដំណាក់កាលអភិវឌ្ឍទៅតាមអាយុកូនរបស់លោកអ្នក។*


សហការផលិតដោយ

ក្រោមជំនួយឧបត្ថមពី រដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី ACCESS

Australian Aid

ACCESS Sustainable quality services for all


1.Flashcard_Level1_V6_Khmer.indd 17 9/6/23 1:05 PM

# បណ្ណលេខ៨: អ្នកព្យាបាលចូលរួមលើសពីម្នាក់ ដោយផ្អែកជាចំបង លើភាពរួចរាល់ជាស្រេចក្នុងការចូលរៀន









**អ្នកព្យាបាលមានច្រើនលើសពីម្នាក់** ដូចជា អ្នកព្យាបាលភាសា ព្យាបាលមុខងារប្រចាំថ្ងៃ និងក្រុមជួយអន្តរាគមន៍ឲ្យបានទាន់ពេលវេលា ត្រូវការជួយកុមារអូទីស្សឹម ដើម្បីទទួលបានជំនាញចាំបាច់សម្រាប់ចាប់ផ្តើមចូលរៀន។ **រដ្ឋា** គឺមានតម្រូវការផ្សេងៗ ដូច្នេះ តម្រូវឲ្យមានការព្យាបាលច្រើនយ៉ាងដោយធ្វើការជាមួយគ្នា ដើម្បីធ្វើផែនការដែលតម្រូវនឹងសេចក្តីត្រូវការរបស់កុមារម្នាក់ៗ។ ផែនការអប់រំជាលក្ខណៈបុគ្គលជួយឲ្យ**រដ្ឋា**ចូលរៀន និងទ ទួលបានជំនាញសក្តានុពលពេញលេញរបស់គាត់។ អ្នកព្យាបាលបានជួយឲ្យក្រុមគ្រួសាររបស់**រដ្ឋា** នូវឧបករណ៍ផ្សេងៗ និងការគាំទ្រ ដែលគេត្រូវការ ដើម្បីសម្រួលដល់ការសិក្សានៅផ្ទះ និងនៅសាលារៀន។ ការចូលរួមយ៉ាងសកម្មជាមួយក្រុមគ្រួសាររបស់កុមារ គឺការស្វែងយល់ និងចូលរួមគាំទ្រយ៉ាងសកម្មនៅក្នុងដំណើរការព្យាបាល។

1.Flashcard_Level1_V6_Khmer.indd 18 9/6/23 1:05 PM

# ព័ត៌មានបន្ថែម៖

**នេះជាឧទាហរណ៍មួយចំនួន ដែលកុមាររដ្ឋាត្រូវបានជួយពីអ្នកព្យាបាលច្រើនលើសពីម្នាក់ ដើម្បីឲ្យគាត់មានភាពរួចរាល់ក្នុងការចូលរៀន៖**

- ពេទ្យដែលទទួលបានការបណ្ដុះបណ្ដាល បានធ្វើការវាយតម្លៃសមត្ថភាពរបស់**រដ្ឋា** ដើម្បីឲ្យគាត់អនុវត្តសកម្មភាពប្រចាំថ្ងៃរបស់គាត់ ដូចជា ដុសធ្មេញ ងូតទឹក និងស្លៀកពាក់ និងបណ្ដុះបណ្ដាលឪពុកម្ដាយដើម្បីបង្រៀនជំនាញទាំងនេះនៅផ្ទះ។ ធ្វើដូចនេះ ដើម្បីឲ្យ**រដ្ឋា**ត្រៀមខ្លួនរួចរាល់សម្រាប់ចូលរៀន។
- អ្នកព្យាបាលមុខងារប្រចាំថ្ងៃ អាចជួយឲ្យកុមារអូទីស្សឹម មានភាពប្រសើរឡើងចំពោះជំនាញចលនាតូច(ម្រាមដៃ) និងការសម្របសម្រួលចលនា ដើម្បីឲ្យកុមារទទួលបានសមត្ថភាពក្នុងការសរសេរ ដែលជាជំនាញចាំបាច់ក្នុងការចូលរៀន។
- អ្នកអប់រំពិសេស អាចធ្វើការវាយតម្លៃថាតើកុមារអូទីស្សឹមមានសមត្ថភាពរៀនជំនាញថ្មីៗ និងអាកប្បកិរិយានៅក្នុងថ្នាក់រៀនទូទៅ ឬក៏កុមារត្រូវការសាលាអប់រំពិសេស។

**អ្នកព្យាបាលច្រើននាក់ធ្វើការរួមគ្នា** (ដូចក្នុងករណីរដ្ឋា) មានលទ្ធភាពបំពេញតម្រូវការរបស់កុមារម្នាក់ៗ។ ការធ្វើផែនការកុមារម្នាក់ៗ នេះរួមទាំងការកំណត់ទិសដៅសម្រាប់ការអប់រំរបស់កុមារ ក៏ដូចជាយុទ្ធសាស្ត្រផ្សេងៗសម្រាប់ជួយកុមារទាំងនៅផ្ទះ និងសាលារៀន។ ក្រុមគ្រួសារអាចផ្ដល់ព័ត៌មានទៅកាន់អ្នកព្យាបាលអំពីចំណុចខ្លាំង និងចំណុចខ្សោយរបស់កុមារ ក៏ដូចជាចំណង់ចំណូលចិត្តរបស់គេ ដែលជួយក្នុងការបង្កើតផែនការកុមារម្នាក់ៗ។

*នៅពេលដែលម្នាក់ៗ រួមទាំងអ្នកព្យាបាល និងឪពុកម្ដាយធ្វើការរួមគ្នា នោះកុមារអូទីស្សឹម អាចមានការវិវត្តល្អប្រសើរ។*


សហការផលិតដោយ

ក្រោមជំនួយឧបត្ថមពី រដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី ACCESS

Australian Aid

ACCESS Sustainable quality services for all

# បណ្ណលេខ៩(ក): សារៈសំខាន់នៃការចូលរួមរបស់ឪពុកម្ដាយ និងពេលវេលាប្រកបដោយគុណភាព







**ឪពុកម្ដាយជាច្រើនមានភាពតានតឹងចិត្ត ដូចជាក្នុងករណីរដ្ឋា ពួកគាត់មានបទពិសោធន៍ក្នុងការថែទាំកុមារអូទីស្សឹម នេះជាមធ្យោបាយមួយចំនួនដែលឪពុកម្ដាយអាចចូលរួមជាមួយកុមារអូទីស្សឹមរបស់គាត់ ក៏ដូចជាការថែទាំសម្រាប់ខ្លួនគេផ្ទាល់៖**

- អានសៀវភៅរឿងក្នុងពេលជាក់លាក់ជារៀងរាល់ថ្ងៃ ព្រោះកុមារអូទីស្សឹមមិនចូលចិត្តផ្លាស់ប្ដូរ លេងល្បែងដែលសមស្រប ទៅនឹងតម្រូវការញាណរបស់គេ **(ឧទាហរណ៍ ជៀសវាងល្បែងដែលមានសំឡេងខ្លាំងៗ)។**
- ឆ្លៀតពេលចេញទៅខាងក្រៅធ្វើសកម្មភាពដែលគេចូលចិត្តដូចជាការហែលទឹក**(ជៀសវាងទីកន្លែងដែលមានមនុស្សអ៊ូអរដូចជាផ្សារទំនើប)។**
- និយាយជាមួយគេអំពីកាលវិភាគប្រចាំថ្ងៃរបស់គេ ដោយប្រើជារូបភាព ឬរូបថត **(កាលវិភាគបែបរូបភាព)។**

# ព័ត៌មានបន្ថែម៖

**នេះជាឧទាហរណ៍ជាក់លាក់មួយចំនួន ដែលឪពុកម្ដាយរដ្ឋាចូលរួមសកម្មភាពជាមួយកូនរបស់គាត់:**

- ឪពុកម្ដាយ**រដ្ឋា**មានសៀវភៅរឿងមួយចំនួន ដែលគាត់អាចជ្រើសរើសយកសៀវភៅមួយក្បាលណាមួយ ដើម្បីអានជាមួយកូនគាត់ជារៀងរាល់ថ្ងៃ។ សកម្មភាពនេះ អាចធ្វើឲ្យក្រុមគ្រួសារសប្បាយរីករាយជាមួយនឹងពេលវេលាប្រកបដោយគុណភាព ក៏ដូចជាបានអភិវឌ្ឍជំនាញភាសារបស់គេ។
- ល្បែងលេង ដូចជាលេង អ៊ូមវ៉ាក់អឺ  និងលេងបិទពួន គឺមានភាពរីករាយចំពោះ **រដ្ឋា**នៅក្នុងជីវិតដំបូងរបស់គាត់ ដែលជួយគាត់អភិវឌ្ឍជំនាញសង្គម និងសម្របសម្រួលចលនា។
- ចេញទៅដើរលេងនៅខាងក្រៅជាប្រចាំ ដូចជា ទៅកន្លែងសួនទឹក ជួយឲ្យ**រដ្ឋា**ផ្លាស់ប្តូរបទពិសោធន៍ថ្មីៗ ទទួលបានជំនាញចលនា ក៏ដូចជារៀនសូត្រពីពិភពខាងក្រៅនៅជុំវិញខ្លួនគាត់។


សហការផលិតដោយ

ក្រោមជំនួយឧបត្ថមពី រដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី ACCESS

# បណ្ណលេខ៩ (ខ): សារៈសំខាន់នៃការចូលរួមរបស់ឪពុកម្ដាយ និងពេលវេលាប្រកបដោយគុណភាព








• ចំណាយពេលជាមួយគេ ដោយរីករាយជាទៀងទាត់ (**ពេលវេលាប្រកបដោយគុណភាព**) ដោយមានការចូលរួមជាមួយ នឹងកូនរបស់ពួកគាត់ក្នុងពេលវេលាជាក់លាក់ជារៀងរាល់ថ្ងៃ ដោយមានភាពសប្បាយរីករាយទាំងអស់គ្នា(**ពេលវេលាប្រកបដោយគុណភាព**) ឪពុកម្ដាយអាចកាត់បន្ថយភាពតានតឹងចិត្តរបស់ពួកគាត់ដោយខ្លួនឯង និងបង្កើនទំនាក់ទំនងប្រកបដោយក្ដីស្រឡាញ់។ ពេលវេលាប្រកបដោយគុណភាពគឺជាពេលវេលាដែលឪពុកម្ដាយចំណាយពេលជាមួយកូនរបស់គាត់ ដោយផ្ដោតលើការបង្កើតទំនាក់ទំនង និងភាពសប្បាយរីករាយដូចជាការអានសៀវភៅរួមគ្នា លេងល្បែង ឬដើរលេងខាងក្រៅ ។

1.Flashcard_Level1_V6_Khmer.indd 22 9/6/23 1:05 PM

# ព័ត៌មានបន្ថែម៖

- ដាក់កាលវិភាគប្រចាំថ្ងៃជារូបភាព យកទៅបិទនៅក្នុងបន្ទប់របស់**រដ្ឋា** ដែលងាយស្រួលនិយាយជាមួយគាត់អំពីសកម្មភាពប្រចាំថ្ងៃរបស់គាត់។ នេះជាវិធីប្រសើរបំផុត ដើម្បីជួយគាត់យល់ពីសកម្មភាពផ្សេងៗ និងការផ្លាស់ប្តូរពេលវេលា នៅក្នុងចន្លោះថ្ងៃនីមួយៗ។ ជាធម្មតាការចំណាយពេលជាមួយ**រដ្ឋា** គឺមានភាពសប្បាយរីករាយសម្រាប់បងស្រី ក៏ដូចជាឪពុកម្តាយរបស់គាត់ផងដែរ។ ធ្វើដូចនេះ **រដ្ឋា**ដឹងថា សមាជិកក្រុមគ្រួសារគាត់ស្រឡាញ់គាត់ ទទួលស្គាល់ និងឲ្យតម្លៃគាត់ បើទោះជាគាត់មានផលលំបាកក៏ដោយ។

*នៅពេលឪពុកម្តាយ ផ្តល់ពេលវេលាប្រកបដោយគុណភាព កុមារអូទីស្សឹមមានអារម្មណ៍ថា មានសុវត្ថិភាព និងការស្រឡាញ់ ដែលទាំងនេះមានសារៈសំខាន់ចំពោះការអភិវឌ្ឍរបស់គេ។*

សហការផលិតដោយ

ក្រោមជំនួយឧបត្ថមពី រដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី ACCESS

# របៀបប្រើបណ្ណប្រធានបទទី១: ការយល់ដឹងពីអូទីស្សឹម និងការជួយអន្តរាគមន៍ឲ្យបានទាន់ពេលវេលា

**១. តើបណ្ណទាំងនេះមានសារៈសំខាន់ៗអ្វីខ្លះ?**

សន្លឹកបណ្ណទាំងនេះពន្យល់ពីអ្វីទៅជា វិបល្លាសអូទីស្សឹម (ASD) រោគសញ្ញាសំខាន់ ការកត់សម្គាល់បញ្ហា និងជួយអន្តរាគមន៍ឲ្យបានទាន់ពេលវេលា ការចូលរៀនដំបូងនិងជួយអន្តរាគមន៍ នៅផ្ទះ។

**២. តើអ្នកណានឹងទទួលបានអត្ថប្រយោជន៍ពីបណ្ណទាំងនេះ (ក្រុមគោលដៅ)?**

ឪពុកម្តាយ គ្រូមត្តេយ្យសិក្សា បុគ្គលិកថែទាំសុខភាពបឋម បុគ្គលិកថែទាំសុខភាពតាមសហគមន៍ ប្រធានភូមិ និងឃុំ។

**៣. ការជម្រាបព័ត៌មាន និងរៀបចំសម្រាប់ការផ្សព្វផ្សាយ (ការចូលរួមពីសហគមន៍)៖**

- ជ្រើសរើសទីកន្លែងស្ងាត់
- ជូនដំណឹងដល់អ្នកចូលរួមជាមុនពីទីតាំង និងគោលបំណងនៃការប្រជុំផ្សព្វផ្សាយ
- ជាការល្អ ឲ្យមានការចូលរួមពីឪពុកម្តាយដែលមានកូនអូទីស្សឹមក្នុងការពិភាក្សា (ជាអ្នកដឹកនាំក្រុមមិត្តភក្តិ)
- ជូនដំណឹងដល់ប្រធានភូមិ និងឃុំ ពីគោលបំណង និងទទួលបានការយល់ព្រមសម្រាប់ការប្រជុំផ្សព្វផ្សាយ

**៤. របៀបប្រើកាតទាំងនេះ (ដំណើរការទំនាក់ទំនងផ្លាស់ប្តូរអាកប្បកិរិយា)**

- ចំនួនអ្នកចូលរួមពី ១០ ទៅ ១៥នាក់ ជាចំនួនល្អ
- ជាការប្រសើរ ត្រូវមានកាតពីរឈុត ក្នុងករណីមានដែលមនុស្សច្រើនចូលរួម
- ចែកកាតម្នាក់មួយសន្លឹក
- ទុកពេលឱ្យពួកគាត់អានដោយខ្លួនឯង មុនពេលចាប់ផ្តើមការពិភាក្សា

**៥. ប្រធានបទនៅក្នុងឈុតកាត កម្រិតលេខ ១ (មាតិកា)៖**

- **បណ្ណលេខ១:** តើអ្វីទៅជាអូទីស្សឹម?
- **បណ្ណលេខ២:** សញ្ញា និងរោគសញ្ញានៃអូទីស្សឹម?

- **បណ្ណលេខ៣:** ការកត់សម្គាល់បញ្ហាឲ្យបានទាន់ពេលវេលា
- **បណ្ណលេខ៤:** អូទីស៊ីម ជាវិបល្លាសការអភិវឌ្ឍខួរក្បាល និងមិនមែនជាជំងឺនោះទេ
- **បណ្ណលេខ៥:** ប្រភេទនៃបញ្ហាបន្ថែម (បញ្ហារួមផ្សំផ្សេងៗ)
- **បណ្ណលេខ៦:** មិនមានការព្យាបាលនោះទេ ប៉ុន្តែអាចជួយបាន
- **បណ្ណលេខ៧:** ការជួយអន្តរាគមន៍តាមរយៈការលេង
- **បណ្ណលេខ៨:** អ្នកព្យាបាលច្រើនជាងម្នាក់ចូលរួម
- **បណ្ណលេខ៩:** សារៈសំខាន់នៃការចូលរួមរបស់ឪពុកម្ដាយ និងពេលវេលាប្រកបដោយគុណភាព

**៦. របៀបផ្សព្វផ្សាយ សង្ខេប និងបញ្ចប់ជំនួប (គោលការណ៍រៀនសូត្រដែលមានលក្ខណៈចូលរួម)៖**

- សួរថា តើអ្នកចូលរួមត្រៀមខ្លួនហើយ ឬនៅ ឬត្រូវការពេលវេលាអានកាតរឿងខ្លួនបន្ថែម?
- អ្នកចូលរួមម្នាក់ៗអានបណ្ណ ឬចែករំលែកសាច់រឿងនៅលើទំព័រទីមួយ។
- អ្នកសម្របសម្រួលផ្ដល់ព័ត៌មានបន្ថែមលើបណ្ណនីមួយៗ (បង្ហាញនៅផ្នែកខាងក្រោយ)។
- ផ្ដល់ឱកាសសម្រាប់ការពិភាក្សា និងបញ្ជាក់ឲ្យបានច្បាស់លាស់សិនមុនទៅបណ្ណបន្ទាប់។
- ស្នើសុំឱ្យមានអ្នកចូលរួមម្នាក់សង្ខេបការពិភាក្សា។
- អ្នកសម្របសម្រួលឆ្លើយតបនឹងសំណួរ ផ្ដល់ការបកស្រាយឲ្យបានច្បាស់លាស់ និងគូសបញ្ជាក់សារអប់រំសំខាន់ៗ។
- ពេលបញ្ចប់ សូមសម្រេចចិត្តជ្រើសរើសប្រធានបទ កាលបរិច្ឆេទ និងពេលវេលាសម្រាប់ការប្រជុំ ឬផ្សព្វផ្សាយលើកក្រោយទៀត។
- អ្នកសម្របសម្រួលបញ្ចប់ ដោយថ្លែងអំណរគុណដល់អ្នកចូលរួម។

សហការផលិតដោយ

ក្រោមជំនួយឧបត្ថម្ភពី រដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី ACCESS

Australian Aid

ACCESS

1.Flashcard_Level1_V6_Khmer.indd 25 9/6/23 1:05 PM

# សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង

## អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- អគារលេខ៧៨៨ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
- +៨៥៥-២៣-៧២៧-៤២៨
- +៨៥៥-២៣-៧២៧-៤២៦
- info@dac.org.kh
- www.dac.org.kh
- ក្រុមប្រឹក្សាសកម្មភាពជនពិការ-Disability Action Council

## មជ្ឈមណ្ឌលសុខភាពផ្លូវចិត្តកុមារ និងយុវជន (ការីតាស ម.ស.ផ.ក)

- មន្ទីរពេទ្យបង្អែកជ័យជំនះ តាខ្មៅ ខេត្តកណ្ដាល
- +៨៥៥-២៣-៩៨៣-៣៤៨
- +៨៥៥-៩២-៨៩៥-៤៦៦
- ccamh-admin@caritascambodia.org
- caritascambodia.org
- www.CCAMH Cambodia

1.Flashcard_Level1_V6_Khmer.indd 26 9/6/23 1:05 PM

